**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ:** ១៣១៧ សជណ

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ** : សេចក្ដីជូនដំណឹងស្ដីពីខ្លឹមសារអនុសាសន៍០៨ចំណុចរបស់សម្ដេចអគ្គមហាសេនាបតីតេជោ**ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ។

**យោង:** -លិខិតលេខ ៤៨៧ ក.ក.ជ របស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤។

-ចំណារដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤។

សេចក្តីដូចមានចែងតាមកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា ៖ ដើម្បីពង្រឹងការអនុវត្ត **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨** និងក្នុងគោលបំណងពង្រឹងកិច្ចសហការសម្របសម្រួលជាមួយនិងក្រសួង-ស្ថាប័ននិងអង្គការជាតិ និងអន្តរជាតិឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ធានាបានជោគជ័យ រាជរដ្ឋាភិបាលសូមឱ្យក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្តោតការយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗមួយចំនួនទៀតដូចខាងក្រោមនេះ៖

***ទី១.*** ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវសម្របសម្រួលការដឹកនាំអនុវត្តន៍គម្រោង និងកម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើអាទិភាពនានា ដែលបានគូសបញ្ជាក់នៅក្នុង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ**នេះ និងធានាលើកកម្ពស់សុខដុមនីយកម្មទៅនឹងកម្មវិធីផ្សេងៗទៀត និងពង្រឹងកិច្ចគាំទ្ររបស់ដៃគូអភិវឌ្ឍន៍នានា ក្នុងវិស័យនេះ ឱ្យបានជាអតិបរមា ។

***ទី២.*** ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវរៀបចំបង្កើតផែនការសកម្មភាពមួយច្បាស់លាស់ ដើម្បីធានាអនុវត្តបណ្តាសកម្មភាពជាអាទិភាពនានា ដែលមានចែងក្នុងឯកសារយុទ្ធសាស្ត្រជាតិនេះ ។

***ទី៣.*** ត្រូវរៀបចំបង្កើតកម្មវិធីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងយន្តការផ្តល់របាយការណ៍មួយសមស្រប ដើម្បីធានាឱ្យការអនុវត្តយុទ្ធសាស្ត្រជាតិនេះ ទទួលបាននូវប្រសិទ្ធភាព និងដើម្បីពិនិត្យបន្តកែលម្អគោលនយោបាយ កម្មវិធីក្នុងគោលបំណងអនុវត្តសកម្មភាព និងអន្តរាគមន៍ឱ្យរឹតតែមានប្រសិទ្ធភាពថែមទៀត ។

***ទី៤.*** ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ត្រូវបន្តនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាលើយុទ្ធនាការផ្លាស់ប្តូរទម្លាប់ និងឥរិយាបថរបស់ប្រជាជន ដើម្បីឱ្យបានយល់ជ្រួតជ្រាបថា ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ គឺជាជម្រើសដ៏ល្អ និងប្រកបដោយសុខុមាលភាព ជាជាងការបំបៅកូនដោយទឹកដោះសិប្បនិម្មិត និងត្រូវបង្កើតឱ្យមានសហគមន៍ និងមន្ទីរពេទ្យស្រឡាញ់ទារកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

***ទី៥.*** ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវសហការគ្នាជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំទិវាជាតិអាហារូបត្ថម្ភដែលនឹងត្រូវប្រារព្ធធ្វើជារៀងរាល់ឆ្នាំនាថ្ងៃទី៦ខែវិច្ឆិកាដើម្បីលើកកម្ពស់ការយល់ដឹងពីអាហារូបត្ថម្ភនៅទូទាំងប្រទេសស្របគ្នាជាមួយនឹងទិវាយល់ដឹងអាហារូបត្ថម្ភពិភពលោក ។

***ទី៦.*** គ្រប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដែលបាន និងកំពុងធ្វើការលើសុវត្ថិភាពចំណីអាហារ ត្រូវបង្កើនកិច្ចសហការគ្នាឱ្យបានល្អប្រសើរ ដើម្បីធានាថាទាំងស្បៀងអាហារនាំចូល និងស្បៀងអាហារផលិតនៅក្នុងប្រទេសកម្ពុជា ត្រូវតែមានសុវត្ថិភាពខ្ពស់ និងគុណភាពល្អ ដើម្បីជៀសវាងគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាពលរដ្ឋ និងជាពិសេស ដើម្បីការពារកុមារឱ្យចៀសផុតពីជំងឺផ្សេងៗ និងបញ្ហាកង្វះអាហារូបត្ថម្ភ ។

***ទី៧.*** ត្រូវជំរុញការផ្គត់ផ្គង់ទឹកស្អាតនៅជនបទ ការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យនៅតាមសាលារៀន មណ្ឌលសុខភាព ផ្សារ និងសួនកំសាន្តនានា និងការលើកកម្ពស់អនាម័យ ដោយការលាងសម្អាតដៃជាមួយនឹងសាប៊ូ ដើម្បីកាត់បន្ថយជំងឺនានាដែលបណ្តាលមកពីការប្រើប្រាស់ទឹកកខ្វក់ និងការរស់នៅគ្មានអនាម័យដែលនឹងរួមចំណែក សំខាន់ផងដែរដល់ការផ្តល់អាហារូបត្ថម្ភកុមារ និងមាតា ។

***ទី៨.*** ត្រូវបង្កើតឱ្យមានគោលនយោបាយជាតិ គោលការណ៍ណែនាំបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានាក្នុងការលើកកម្ពស់គុណភាពចំណីអាហារឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព។ ក្នុងនោះការពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារដែលសមស្រប មានដូចជាការបញ្ចូលជីវជាតិអាទៅក្នុងប្រេងឆា ការបញ្ចូលមីក្រូសារជាតិចម្រុះទៅក្នុងអង្ករ ការបញ្ចូលអ៊ីយ៉ូដទៅក្នុងអំបិល ការបញ្ចូលជាតិដែកទៅក្នុងទឹកត្រី ទឹកស៊ីអ៊ីវជាដើម ដែលការដាក់បញ្ចូលកម្រិត ឬបរិមាណមីក្រូសារជាតិនីមួយៗត្រូវស្របតាមស្តង់ដារជាតិ និងជំរុញឱ្យមានការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិឱ្យបានទូលំទូលាយនៅទូទាំងប្រទេស។ ទន្ទឹមនេះ ត្រូវតាមដាន ត្រួតពិនិត្យគុណភាពនៃផលិតផលដែលមានបញ្ចូលមីក្រូសារជាតិ ឱ្យបានជាប់ជាប្រចាំ និងចាត់វិធានការភ្លាមៗ ក្នុងករណីផលិតផលដែលបានបង្កគ្រោះថ្នាក់ដល់សុខភាពប្រជាពលរដ្ឋ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាជ្រាប និងចាត់ចែងអនុវត្ត តាមការគួរ ។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ប៊ុន_អ៊ុយ

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តមអភិបាលនៃគណអភិបាលគ្រប់ខេត្ត និងរាជធានី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
- ឯកសារ-កាលប្បវត្តិ